ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...... សហវ.ប្រក

# ប្រកាសរួម
## ស្តីពី
## ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែង ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**ប្រការ១.–**

ប្រកាសនេះមានគោលបំណងកំណត់យន្តការ ដើម្បីធានាប្រសិទ្ធភាពនៃការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

**ប្រការ២.–**

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "ទ្រព្យសម្បត្តិរឹបអូស" រួមមាន ៖

១. ចលនទ្រព្យ

-បរិក្ខារផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យបច្ចេកទេសផ្សេងៗ

-យានយន្តមធ្យោបាយធ្វើដំណើរ និងគ្រឿងចក្រ

-សង្ហារឹម សម្ភារៈ

២. អចលនទ្រព្យ

- ដី
- អគារ
- ទ្រព្យសម្បត្តិដែលភ្ជាប់នឹងអគារ

៣. ទ្រព្យជាតេនវត្ថុ និងទ្រព្យដទៃទៀត ដែលក្រោយពីមានសាលក្រមស្ថាពររបស់តុលាការបានបង្គាប់ជាទ្រព្យសម្បត្តិរដ្ឋ។

ដោយឡែកការចាត់ចែងគ្រឿងញៀនត្រូវអនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣.–**

ត្រូវបានបង្កើត គណៈកម្មការអន្តរក្រសួងស្ថាប័នមួយ សម្រាប់រៀបចំដំណើរការពាក់ព័ន្ធនឹងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "គណៈកម្មការ"។

**ប្រការ៤.–**

គណៈកម្មការមានសមាសភាពចូលរួម ដូចខាងក្រោម៖

| | |
|---|---|
| –តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| –តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | អនុប្រធាន |
| –តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| –តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ | សមាជិក |
| –តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណៈកម្មការ ប្រើប្រាស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ អង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័នដូចក្នុងប្រការ ៤ នៃប្រកាសនេះជាលេខាធិការដ្ឋានតាមការចាំបាច់។

**ប្រការ៥.–**

គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការក្នុងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ
- ធ្វើការកត់ត្រា បញ្ជីសារពើភណ្ឌ ផ្ទៀងផ្ទាត់ និងបញ្ជាក់ពីភាពត្រឹមត្រូវលើទ្រព្យសម្បត្តិរឹបអូសដែលមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលបញ្ជីទ្រព្យសម្បត្តិ និងឯកសារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- ត្រូវបញ្ជូនបញ្ជីទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ទៅប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឬ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រគល់ជូន។

**ប្រការ៦.–**

គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានតាមការចាំបាច់។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមានសិទ្ធិកោះប្រជុំតាមលិខិតប្រគល់សិទ្ធិ។

ក្នុងករណីចាំបាច់ គណៈកម្មការអាចអញ្ជើញភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំ និងចូលរួមបំពេញការងារជាមួយគណៈកម្មការ តាមការជាក់ស្តែង។

**ប្រការ៧.-**

ក្រោយពីមានសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវលើកសំណើសុំលក់ទ្រព្យសម្បត្តិរឹបអូសមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច និងក្នុងករណីចាំបាច់ ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាល។ នីតិវិធីនៃការលក់ទ្រព្យសម្បត្តិរឹបអូស ត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃ ឬ នីតិវិធីពិគ្រោះថ្លៃដូចមានចែងក្នុងប្រកាសរួមនេះ។

**ប្រការ៨.-**

ក្រោយទទួលបានគោលការណ៍ គណៈកម្មការត្រូវធ្វើការសិក្សា វាយតម្លៃលើទ្រព្យសម្បត្តិរឹបអូស ដើម្បីកំណត់តម្លៃមូលដ្ឋានសម្រាប់ដាក់លក់។ ការវាយតម្លៃនៃទ្រព្យសម្បត្តិរឹបអូសត្រូវផ្អែកលើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម៖

១. ចលនទ្រព្យជាបរិក្ខារឧស្សាហកម្ម និងបច្ចេកទេស យានយន្ត គ្រឿងចក្រ សង្ហារឹម និងឧបករណ៍សម្ភារៈត្រូវកំណត់តាមស្ថានភាព គុណភាព និងតម្លៃនៅសល់ជាក់ស្តែង។

២. អចលនទ្រព្យ

- ទំហំដី និង អគារ តាមប្លង់ ឬការកំណត់របស់សុរិយោដី
- ទីតាំង និងស្ថានភាពដី និងលក្ខណៈ គុណភាព អាយុកាលរបស់អគារ
- តម្លៃដី និងអគារតាមទិន្នន័យតម្លៃទីផ្សារជាក់ស្តែងប្រៀបធៀបនឹងតម្លៃរបស់ក្រុមហ៊ុនអចលនទ្រព្យ

៣. ចំពោះទ្រព្យជារតនវត្ថុ និងទ្រព្យដទៃទៀតដែលគ្មានតម្លៃទីផ្សារ គណៈកម្មការត្រូវវាយតម្លៃតាមយថាប្រភេទជាក់ស្តែងនៃទ្រព្យនោះ។

គណៈកម្មការ ត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការវាយតម្លៃនេះ ដោយមានចុះហត្ថលេខាពីគ្រប់សមាជិកចូលរួម និងដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងឯកភាព។

**ប្រការ៩.-**

គណៈកម្មការ ត្រូវរៀបចំចាត់ចែងកិច្ចដំណើរការលក់ដេញថ្លៃ ទ្រព្យសម្បត្តិរឹបអូសតាមនីតិវិធីដេញថ្លៃជាសាធារណៈ ចាប់ពីតម្លៃមូលដ្ឋានឡើង ដោយដាក់ក្នុងស្រោមសំបុត្រ ឬផ្ទាល់មាត់ ដែលអាស្រ័យលក្ខណៈ និងវិសាលភាព នៃទ្រព្យសម្បត្តិរឹបអូស និងតាមការជ្រើសរើសរបស់គណៈកម្មការ។

មូលដ្ឋាននៃការដេញថ្លៃត្រូវកំណត់ក្នុងសៀវភៅបន្ទុក ដែលរៀបចំដោយគណៈកម្មការ និងត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១០.-**

សៀវភៅបន្ទុកត្រូវមានកំណត់ច្បាស់លាស់នូវចំណុចសំខាន់ជាអាទិ៍៖

- កម្មវត្ថុនៃការដេញថ្លៃ
- កាលបរិច្ឆេទ និងទីកន្លែង
- ទ្រព្យសម្បត្តិជាកម្មវត្ថុនៃការដាក់ឱ្យដេញថ្លៃ (រូបទ្រព្យ ទីកន្លែង ចំនួន ទំហំលក្ខណៈ គុណភាព។ល។)
- តម្លៃមូលដ្ឋាន

- លក្ខខណ្ឌជ្រើសរើសអ្នកចូលរួមដេញថ្លៃ
- ការកក់ប្រាក់ធានាចំនួន ១០% (ដប់ភាគរយ) នៃតម្លៃមូលដ្ឋាន
- កម្មវិធីនៃការបង់ប្រាក់
- ការប្រគល់ទទួល
- វិធីដេញថ្លៃជាសាធារណៈ (ដោយដាក់ក្នុងស្រោមសំបុត្រ ឬផ្ទាល់មាត់)
- របៀបរបប និងបទបញ្ញាក្នុងកិច្ចដំណើរការដេញថ្លៃ
- បំរាមផ្សេងៗ (ការឃុបឃិតក្នុងបំណងបង្ខូចតម្លៃ ។ល។)
- ការរឹបអូសប្រាក់កក់
- ការផ្ទេរសិទ្ធិចូលរួមដេញថ្លៃ

**ប្រការ១១.–**

ការផ្សព្វផ្សាយសេចក្តីជូនដំណឹងពីការដេញថ្លៃ ត្រូវធ្វើតាមរយៈវិទ្យុផ្សាយសម្លេង ទូរទស្សន៍ សារព័ត៌មាន ការបិទផ្សាយនៅតាមក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គភាពនានា។

**ប្រការ១២.–**

គណៈកម្មការជាអ្នកដឹកនាំ ចាត់ចែងកិច្ចដំណើរការដេញថ្លៃទ្រព្យសម្បត្តិរឹបអូសតាមការកំណត់ក្នុងសៀវភៅបន្ទុក។ ការដេញថ្លៃចាប់ពីតម្លៃមូលដ្ឋានឡើងទៅ ដែលត្រូវដាក់តម្លៃចំនួនបីលើក ។ ការដាក់តម្លៃរបស់បេក្ខជន ត្រូវធ្វើឡើងដោយសម្ងាត់ និងមានចុះហត្ថលេខាដាក់ក្នុងស្រោមសំបុត្របិទជិតដែល

- លើកទី១ ចាប់ពីតម្លៃមូលដ្ឋានឡើងទៅ
- លើកទី២ ចាប់ពីតម្លៃនៃលទ្ធផលនៃការដេញថ្លៃលើកទី ១ ដែលត្រូវបង្កើន ១០% (ដប់ភាគរយ)
- លើកទី៣ ចាប់ពីតម្លៃនៃលទ្ធផលនៃការដេញថ្លៃលើកទី ២ ដែលត្រូវបង្កើន ១០% (ដប់ភាគរយ)

ក្នុងករណីការដេញថ្លៃចំនួន ០៣ លើករួចហើយ ប៉ុន្តែមិនទាន់ទទួលបានលទ្ធផលជាស្ថាពរនោះត្រូវដំណើរការដេញថ្លៃបន្តទៀតរហូតទទួលបានលទ្ធផលឈ្នះលើការដេញថ្លៃមានតែមួយ។

ករណីដំណើរការដេញថ្លៃមិនមានភាពរលូនតាមសៀវភៅបន្ទុក ឬ មានភាពមិនប្រក្រតី ដូចជាការឃុបឃិតគ្នាបង្ខូចតម្លៃ ហើយដែលមានភស្តុតាង លទ្ធផលដេញថ្លៃត្រូវទុកជាមោឃៈ។ គណៈកម្មការត្រូវរៀបចំការដេញថ្លៃសារជាថ្មី។ បន្ទាប់ពីពិនិត្យឃើញថា ការដេញថ្លៃប្រព្រឹត្តទៅដោយប្រក្រតី តម្លាភាព និងយុត្តិធម៌ នោះគណៈកម្មការត្រូវប្រកាសលទ្ធផលនៃការដេញថ្លៃ ដោយប្រកាសរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលហ៊ានឱ្យតម្លៃខ្ពស់ជាងគេ ។

ករណីអ្នកឈ្នះការដេញថ្លៃ បោះបង់ចោលលទ្ធផលដេញថ្លៃ នោះប្រាក់កក់ចូលដេញថ្លៃត្រូវរឹបអូស។ ករណីនេះ គណៈកម្មការត្រូវចរចាជាមួយអ្នកឈ្នះការដេញថ្លៃបន្ទាប់ពីអ្នកឈ្នះទី១ ដែលបោះបង់ចោលលទ្ធផលនៃការដេញថ្លៃ។

គណៈកម្មការត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ ដោយមានចុះហត្ថលេខាពីគ្រប់សមាសភាពគណៈកម្មការ ដែលបានចូលរួម និងផ្តិតមេដៃរបស់អ្នកដេញថ្លៃបាន។

កំណត់ហេតុនៃការដេញថ្លៃត្រូវដាក់សុំការពិនិត្យ និងសម្រេច ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ត្រូវសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាលលើលទ្ធផលនៃការដេញថ្លៃបណ្តោះអាសន្ន និងតាមនេះ លទ្ធផលដេញថ្លៃបណ្តោះអាសន្ន ត្រូវចាត់ទុកជាលទ្ធផលស្ថាពរ។

**ប្រការ១៣.-**

នីតិវិធីពិគ្រោះថ្លៃ ដើម្បីលក់ទ្រព្យសម្បត្តិរឹបអូសត្រូវផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានគោលការណ៍ពីរាជរដ្ឋាភិបាលឲ្យលក់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ
- ការដេញថ្លៃមិនទទួលបានលទ្ធផល
- មានរូបវន្តបុគ្គល ឬ នីតិបុគ្គលតែមួយដាក់ពាក្យដេញថ្លៃ
- ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់ មានភ្ជាប់លក្ខខណ្ឌត្រូវដោះស្រាយដូចជា កាតព្វកិច្ចជានាទូទាត់សងបំណុលជំនួស កាតព្វកិច្ចដោះស្រាយគោលនយោបាយ ឬ កាតព្វកិច្ចមួយចំនួនទៀតដែលតម្រូវ
- ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់មានលក្ខណៈពិសេស ទាមទារឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន មានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការទទួលយក។

**ប្រការ១៤.-**

គណៈកម្មការត្រូវរៀបចំកិច្ចសន្យាលក់ជាមួយអ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. លក្ខខណ្ឌនៃការទូទាត់ :

អ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃបានត្រូវធ្វើការបង់យ៉ាងច្រើនជាបីដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវបង់យ៉ាងតិចចំនួន៣០% (សាមសិបភាគរយ)។

២. លក្ខខណ្ឌនៃការប្រគល់ទទួល:

ក. គណៈកម្មការចេញលិខិតប្រគល់ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់ ជូនអ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃ បានក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃធ្វើការ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌនៃការទូទាត់ និងលក្ខខណ្ឌដទៃទៀតដែលគណៈកម្មការបានកំណត់ចប់ជាស្ថាពរ

ខ. អ្នកដេញថ្លៃបានត្រូវចុះហត្ថលេខា ឬ ផ្តិតមេដៃលើឯកសារពាក់ព័ន្ធ ដើម្បីបញ្ជាក់អំពីភាពស្របច្បាប់នៃការទទួលខុសត្រូវលើទ្រព្យសម្បត្តិដែលដេញបាន។

**ប្រការ១៥.-**

ចំពោះករណីលក់ចលនទ្រព្យ មធ្យោបាយដឹកជញ្ជូន គ្រឿងចក្រ និង ឧបករណ៍សម្ភារៈ បន្ទាប់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានចាត់ចែងការទូទាត់តម្លៃទិញ និងបំពេញកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាលក់បានចប់សព្វគ្រប់ គណៈកម្មការត្រូវប្រគល់រូបទ្រព្យទាំងនោះ ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដើម្បីទទួលបានការកាន់កាប់តាមច្បាប់កំណត់ ។

ចំពោះករណីលក់ដី និងអគារ បន្ទាប់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានទូទាត់ថ្លៃទិញផ្តាច់ បំពេញកាតព្វកិច្ចចែងក្នុងសៀវភៅបន្ទុក កិច្ចសន្យាលក់រួចរាល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចផ្ទេរដី និងអគារដែលលក់ផ្តាច់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន ដើម្បីបំពេញបែបបទស្នើសុំសិទ្ធិកាន់កាប់តាមច្បាប់កំណត់។

**ប្រការ១៦.–**

ចំណូលទាំងអស់ដែលបានពីទ្រព្យសម្បត្តិដែលរឹបអូស និងក្រោយធ្វើការចាត់ចែងតាមសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលថវិការដ្ឋ និងត្រូវបែងចែកតាមប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ១៧.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក និង ប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការ និងប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រធានអង្គភាពនានា នៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ[illegible] ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**នាយឧត្តមសេនីយ៍.កែ_គីមយ៉ាន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *សាលារាជធានី ខេត្ត*
- *ដូចប្រការ ១៨*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*